#ZERODISCRIMINATIONDAY

ZERO DISCRIMINATION DAY
1 MARCH 2017

MAKE SOME NOISE

# សេចក្តីថ្លែងការណ៍រួម

*រាជធានីភ្នំពេញ ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧*

## នៅទិវាគ្មានការរើសអើងឆ្នាំ២០១៧ អង្គការសង្គមស៊ីវិលស្នើរដ្ឋាភិបាលកម្ពុជា "កុំទុកនរណាម្នាក់ចោលនៅពីក្រោយ" ការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា

នៅក្នុងឱកាសនៃទិវាគ្មានការរើសអើងឆ្នាំ២០១៧ យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") គោរព ការពារ និងលើកកម្ពស់សិទ្ធិរបស់ក្រុមដែលពុំសូវមានគេយកចិត្តទុកដាក់ដល់ និងក្រុមងាយរងការរើសអើងទាំងអស់នៅកម្ពុជា និងដើម្បីធានាថា "គ្មានអ្នកណាម្នាក់ត្រូវគេទុកចោល" នៅក្នុងការអភិវឌ្ឍនៃប្រទេសកម្ពុជា ស្របតាមរបៀបវារៈនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពឆ្នាំ២០៣០។ យើងខ្ញុំក៏សូមអំពាវនាវផងដែរដល់ប្រជាពលរដ្ឋខ្មែរទាំងអស់មេត្តាទទួលយក និងស្រឡាញ់រាប់អានដល់សមាជិកទាំងឡាយនៃសហគមន៍ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ("អ្នកស្រឡាញ់ភេទដូចគ្នា") ជនពិការ ជនជាតិដើម និងក្រុមជាតិពន្ធភាគតិច ព្រមទាំងក្រុមដែលពុំសូវត្រូវបានគេគិតគូរដទៃទៀតទាំងអស់។

ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧ ជាទិវាគ្មានការរើសអើង ដែលជាគំនិតផ្តួចផ្តើមសកលមួយក្នុងគោលបំណងប្រយុទ្ធប្រឆាំងនឹងការប្រព្រឹត្តពុំត្រឹមត្រូវ ការមាក់ងាយ និងការមិនយកចិត្តទុកដាក់ចំពោះមនុស្សនៅក្នុងសង្គមតាមរយៈការលើកកម្ពស់ការទទួលយក សមភាព និងការប្រព្រឹត្តស្មើគ្នាចំពោះមនុស្សទាំងអស់នៅក្នុងសកលលោក។ ការរើសអើងមានទម្រង់ច្រើនយ៉ាងដូចជា ការរើសអើងពូជសាសន៍ ឬសាសនា រហូតដល់ការរើសអើងដោយផ្អែកលើយេនឌ័រ និន្នាការភេទ ឬអាយុ និងការសម្លុតនៅតាមសាលារៀន ឬនៅកន្លែងការងារ ជាអាទិ៍។[1] ទិវាគ្មានការរើសអើងទទួលស្គាល់ថាការប្រព្រឹត្តពុំត្រឹមត្រូវលើក្រុមភាគតិចគឺជាបញ្ហាសកលមួយ និងហេតុដូច្នេះតាមរយៈមនុស្សគ្រប់រូប សហគមន៍ និងប្រជាជាតិនានាដែលមានកិច្ចសហការរួមគ្នា សិទ្ធិ និងសេរីភាពរបស់សមាជិកសង្គមដែលរងការគាបសង្កត់ អាចទទួលបានការគាំពារ និងការការពារប្រសើរជាងមុន។ ការធានាថាក្រុមទាំងអស់នេះជាដៃគូពេញលេញ និងស្មើភាពគ្នាក្នុងការអភិវឌ្ឍប្រទេសកម្ពុជា គឺជាធាតុផ្សំសំខាន់មួយនៃរបៀបវារៈ ស្តីពីការអភិវឌ្ឍប្រកបដោយនិរន្តរភាពឆ្នាំ២០៣០។

---

[1] ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិនៃសហរដ្ឋអាមេរិក (ទ.អ.ស.អ) ជំរុញឱ្យមនុស្សគ្រប់រូបលើកឡើងពីការគ្មានការរើសអើង (អត្តបទ) (ឆ្នាំ២០១៧) http://bit.ly/2mfvaXH

មានការចងក្រងជាឯកសារយ៉ាងល្អអំពីការប្រឈមរបស់ក្រុមភាគតិចនៅក្នុងពេលថ្មីៗនេះនៅប្រទេសកម្ពុជា។ របាយការណ៍ស្រាវជ្រាវថ្មីៗនេះ បានរកឃើញពីការរើសអើងយ៉ាងរាលដាលដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ[2] ព្រមទាំងផ្អែកលើពូជសាសន៍ផងដែរ។[3] ក្រុមដែលពុំសូវត្រូវបានគិតគូរដល់នៅកម្ពុជា គឺជាក្រុមដែលងាយនឹងរងគ្រោះជាខ្លាំង ដោយសារកង្វះខាតច្បាប់ហាមប្រាមឱ្យបានជាក់លាក់ពីការរើសអើង។ ជំហានសំខាន់មួយក្នុងការកសាងប្រទេសកម្ពុជាដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋានបន្ថែមទៀត គឺការបង្កើតច្បាប់មួយដែលមានលក្ខណៈពេញលេញប្រឆាំងនឹងការរើសអើងដែលជាបញ្ហាអាទិភាព។ ស្របពេលកម្ពុជាកំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនោះ ជារឿងសំខាន់ដែលគ្រប់វិស័យទាំងអស់នៅក្នុងសង្គម រួមទាំងក្រុមដែលពុំសូវមានការយកចិត្តទុកដាក់បំផុត ត្រូវបានអនុញ្ញាតឱ្យបញ្ចេញមតិយោបល់របស់ខ្លួនក្នុងការកំណត់ និងការតម្រែតម្រង់ទិសដៅឆ្ពោះទៅរកការអភិវឌ្ឍ។ យើងខ្ញុំព្រួយបារម្ភចំពោះអ្នកដែលរងផលប៉ះពាល់ដោយការរើសអើងដោយសារឋានៈក្នុងសង្គមរបស់ពួកគេ រួមទាំងអ្នកការពារសិទ្ធិមនុស្ស ដែលត្រូវបានក្រុមការងាររបស់អង្គការសហប្រជាជាតិទទួលបន្ទុកលើបញ្ហាឃុំខ្លួនតាមអំពើចិត្តបានទទួលស្គាល់នាពេលថ្មីៗនេះ។[4] យើងខ្ញុំសូមអំពាវនាវដល់អាជ្ញាធរកម្ពុជាចាត់វិធានការយ៉ាងម៉ឺងម៉ាត់ដើម្បីធានាឱ្យមានការចូលរួមពេញលេញរបស់ក្រុមដែលពុំសូវមានការយកចិត្តទុកដាក់ទាំងឡាយនៅក្នុងការបង្កើតបានជាអភិវឌ្ឍមួយដោយស្មើភាពគ្នាដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។

ទិវាគ្មានការរើសអើងឆ្នាំ២០១៧ នឹងត្រូវប្រារព្ធនៅក្នុងប្រទេសកម្ពុជាដោយមានការចូលរួមយ៉ាងសកម្មពីសម្ពន្ធអង្គការសង្គមស៊ីវិលច្រើនមជ្ឈដ្ឋាន ព្រមទាំងសាធារណជនទូទៅផងដែរ។ កិច្ចពិភាក្សាតាមវិទ្យុ និងការផ្សាយបន្តផ្ទាល់តាមហ្វេសបុកក៏នឹងត្រូវផ្សព្វផ្សាយនៅថ្ងៃប្រារព្ធទិវាគ្មានការរើសអើង។ សារនៃព្រឹត្តិការណ៍ថ្ងៃនេះ គឺការរួមបញ្ចូលគ្រប់មជ្ឈដ្ឋាន ការទទួលយក និងមិត្តភាព។

យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាផ្តល់អាទិភាពខ្ពស់លើការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ព្រមទាំងលើកកម្ពស់ឱ្យមានសង្គមមួយដែលរស់រវើក មានការទទួលយកជាពិសេសចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ការចូលរួមពីគ្រប់មជ្ឈដ្ឋាន និងស្វាគមន៍ប្រកបដោយសោមនស្ស។ ជាពិសេស យើងខ្ញុំសូមស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជាបង្កើតច្បាប់ស្តីពីការប្រឆាំងនឹងការរើសអើងដើម្បីការពារក្រុមទាំងឡាយដែលមិនសូវត្រូវបានគេយកចិត្តទុកដាក់ និងដើម្បីធានាការចូលរួមយ៉ាងពេញលេញរបស់ក្រុមទាំងនេះក្នុងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។

---

[2] សហគមន៍ឥន្ទធនូកម្ពុជា និង ធីអ៊ិនអេស កម្ពុជា "របាយការណ៍ស្រាវជ្រាវអំពីគំនិត អត្តចរិត និងអាកប្បកិរិយាទៅលើអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា (ឆ្នាំ២០១៥)។ របាយការណ៍របស់ ម.ស.ម.ក ស្តីពី ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា" (ឆ្នាំ២០១៦) http://bit.ly/2lO6STe

[3] ក.ដ.ទ, ម.ស.ម.ក, និង ស.ខ.ក.ក.ស.ម.អ "សិទ្ធិជាពលរដ្ឋរបស់ខ្មែរក្រោមនៅកម្ពុជា" (របាយការណ៍) (ឆ្នាំ២០១៧) http://bit.ly/2m08Osw

[4] ក្រុមការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សទទួលបន្ទុកលើបញ្ហាការឃុំខ្លួនតាមអំពើចិត្ត អនុសាសន៍ លេខ ៤៥/២០១៦ ទាក់ទងនឹងលោក នី សុខា លោក ណៃ វ៉ង់ដា លោក យី សុខសាន្ត លោកស្រី លឹម មុនី និងលោក នី ចរិយា (កម្ពុជា) A/HRC/WGAD/2016/45, http://bit.ly/2hhpWV9

សេចក្តីថ្លែងការណ៍រួមនេះ គាំទ្រដោយអង្គការសង្គមស៊ីវិលរួមមាន ៖

*១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា*
*២. អង្គការអនាគតយុវជនកម្ពុជាអាស៊ាន*
*៣. ក្រុមគាំទ្រផ្នែកច្បាប់សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា*
*៤. អង្គការសហការដើម្បីសេវាសង្គម និងអភិវឌ្ឍន៍*
*៥. អង្គការខាណា*
*៦. អង្គការខេមរា*
*៧. អង្គការសេវាសង្គមសុខភាពបុរស*
*៨. អង្គការសកម្មភាពផ្សព្វផ្សាយដើម្បីអប់រំ និងអភិវឌ្ឍន៍*
*៩. អង្គការសុខភាពបុរសកម្ពុជា*
*១០. ក្រុម រឿងខ្ញុំ សំឡេងខ្ញុំ*
*១១. សហគមន៍ឥន្ទធនូកម្ពុជា*
*១២. ក្រុមស្ត្រី និងជំរើស*
*១៣. បណ្តាញយុវជនងាយរងគ្រោះកម្ពុជា*